**ក្រសួងការពារជាតិ**

## សារជូនពរ

### សូមគោរពជូន

### សម្តេចចៅហ្វាហ្វាំង ចរទៀវជ័យ អធិបតីស្រីឋ្ការ គង់ សំអុល ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង ក្នុងពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ

**សម្តេចចៅហ្វាវាំង ជាទីគោរពដ៏ខ្ពង់ខ្ពស់ !**

ក្នុងឱកាសដ៏មង្គលសួស្តីប្រពៃថ្លៃថ្លា ប្រកបដោយសេចក្តីសោមនស្សរីករាយ ក្នុងឱកាសទទួលអំណរបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហានទាំងអស់ នៃកងយោធពលខេមរភូមិន្ទ ក្នុងនាមខ្ញុំនិងភរិយា សូមជូននូវសព្ទសាធុការពរជ័យ បវរសួស្តី សិរីមង្គលវិបុលសុខ មហាប្រសើរ ជូន **សម្តេចចៅហ្វាវាំង** សូមទទួលបាននូវសុខភាពល្អបរិបូរណ៍ កម្លាំងកាយមាំមួន ប្រាជ្ញាឈ្លាសវៃ ជន្មាយុយឺនយូរតរៀងទៅ។

នាឱកាសដ៏ឧត្តុង្គឧត្តមនេះ យើងខ្ញុំទាំងអស់គ្នា សូមសម្តែងនូវសេចក្តីគោរពយ៉ាងជ្រាលជ្រៅបំផុត មិនអាចបំភ្លេចបានចំពោះសកម្មភាពប្រកបដោយគំរូវីរភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចចៅហ្វាវាំង** ដែលកន្លងមកក៏ដូចជាបច្ចុប្បន្ន**សម្តេច**តែងតែបានខិតខំប្រឹងប្រែង យកអស់កម្លាំងកាយចិត្តនិងប្រាជ្ញាស្មារតី ថ្វាយ**ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** និង **សម្តេចព្រះមហាក្សត្រ** ព្រះវររាជ មាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត និងការលះបង់គ្រប់បែបយ៉ាង បម្រើឧត្តមប្រយោជន៍ ជាតិ សាសនា ព្រះមហាក្សត្រ ក្នុងបុព្វហេតុដ៏ថ្លៃថ្លា នៃការការពារឯករាជ្យជាតិ និងបូរណភាពទឹកដី សុខសន្តិភាព ការបង្រួបបង្រួមជាតិ ការលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ ការអភិវឌ្ឍប្រទេសជាតិ ជាពិសេសការដឹកនាំ **ក្រសួងព្រះបរមរាជវាំង** នៃព្រះរាជាណាចក្រកម្ពុជា ឱ្យទទួលបានជោគជ័យយ៉ាងត្រចេះត្រចង់ជាបន្តបន្ទាប់ តាមរយៈកម្មវិធីនយោបាយដ៏ត្រឹមត្រូវ គួបផ្សំភាពប៉ិនប្រសព្វ និងឈ្លាសវៃប្រកបដោយគតិបណ្ឌិត សក្តានុពល ឧត្តមភាព ស្មារតីភក្តីចំពោះជាតិមាតុភូមិ និងព្រះមហាក្សត្រ។

ជាថ្មីម្តងទៀត ក្នុងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ និងកងយោធពលខេមរភូមិន្ទទាំងមូល ក្នុងនាមខ្ញុំនិងភរិយា សូមលើកហត្ថបួងសួងចំពោះគុណបុណ្យព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក សូមព្រះអង្គតាមជួយបីបាច់ថែរក្សាប្រោះព្រំសព្ទសាធុការពរជ័យជូនចំពោះ **សម្តេចចៅហ្វាវាំង** និង **លោកជំទាវ** ព្រមទាំងបុត្រាបុត្រី ចៅប្រុសចៅស្រីជាទីស្រឡាញ់ សូមបានសមប្រកបនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

សូម **សម្តេចចៅហ្វាវាំង ចរទៀវជ័យ អធិបតីស្រីឋ្ការ គង់ សំអុល ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង**ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

ថ្ងៃអង្គារ ១២កើត ខែ ចេត្រ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញថ្ងៃទី ១២ ខែ មេសា ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

សម្តេចពិជ័យសេនា **ទៀ បាញ់**

វិថីហ្សកឌីមីត្រូវ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទ០២៣ ៨៨៣ ២៧៨: generalsec@mod.gov.kh